សហគមន៍

ភ្នំពេញ ប៉ុស្តិ៍

អង្គការក្រៅរដ្ឋាភិបាលកម្ពុជា

មានចេញផ្សាយរៀងរាល់ខែ

# ជំនន់ប៉ះពាល់ធ្ងន់ធ្ងរដល់កុមារ

## ពេលទឹកជំនន់ម្ដងៗ កុមារងាយទទួលរងគ្រោះថ្នាក់ និងបាត់បង់នូវការអប់រំ

Vincent MacIsaac



កុមារាម្នាក់នេះ កំពុងទទូរថង់ប្លាស្ទិកឈរហាលភ្លៀងនៅភូមិល្វា សង្កាត់កោះដាច់ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញកាលពីពេលថ្មីៗនេះ។ រូបថត ហុង មិនា

កុមារ ដែលរស់នៅតាមដងទន្លេ អាចហែលទឹកបាន ប៉ុន្តែកុមារជាច្រើននាក់ដែលរស់នៅកន្លែងមិនធ្លាប់មានទឹកជំនន់កម្រិតខ្ពស់ មិនអាចហែលទឹកបានទេ។ នេះបើយោងតាមលោក Suprivanto នាយកប្រចាំប្រទេសនៃអង្គការ Plan International បានពន្យល់ឲ្យដឹង។

លោកបានបញ្ជាក់ថា៖ «ចំនួនមនុស្សពាក់កណ្ដាលដែលលង់ទឹកស្លាប់ គឺជាកុមារ។ នៅពេលមានគ្រោះមហន្តរាយ ពួកគេជាអ្នកងាយរងគ្រោះបំផុត»។

អ្នកស្រី ពេជ្រ សុផារី អ្នកគ្រប់គ្រងកម្មវិធីនៃអង្គការ Plan ប្រចាំខេត្តសៀមរាប បានរំឭកពីពេលលោកជំរុញប្រជាជនឲ្យចាកចេញពីខ្ទមរបស់ពួកគេ និងផ្លាស់ទៅទីទួលមានសុវត្ថិភាព។ អ្នកស្រីបានឲ្យដឹងថា ប្រជាជនជាច្រើននាក់មិនព្រមចាកចេញទេ។ «ពួកគេមិនជឿយើងទេ។ ពួកគេមិនគិតថា ទឹកនឹងឡើងខ្ពស់ដូច្នេះឡើយ ហើយបន្ទាប់មក វាពិតជាឡើងខ្ពស់មែន»។

គ្រួសារក្រីក្រជាច្រើននាក់មិនមានទូកទេ។ នៅពេលទឹកឡើងដល់ផ្ទះ ឪពុកម្ដាយខ្លះត្រូវកាត់ដើមចេក និងដើមឫស្សីដើម្បីចងធ្វើជាក្បូនយ៉ាងរហ័ស ដើម្បីដឹកជញ្ជូនកូន និងទ្រព្យសម្បត្តិដែលពួកគេអាចជួយសង្គ្រោះបានទៅទីសុវត្ថិភាព។ អ្នកស្រីបានបន្ថែមថា តំបន់សុវត្ថិភាពទាំងនេះមានលក្ខណៈដូចជំរំជនភៀសខ្លួន គឺគ្មានទឹក ជម្រក អាហារ ឬសេវាពេទ្យ និងអនាម័យទេ។ ស្ត្រីម្នាក់ បានសម្រាលទារកនៅក្នុងភក់ដែលមានចម្ងាយប៉ុន្មានសង់ទីម៉ែត្រប៉ុណ្ណោះពីទឹក។

អង្គការ Plan កំពុងបញ្ចប់សកម្មភាពសង្គ្រោះបន្ទាន់ ដែលមានតម្លៃ ១៧៥-០០០ ដុល្លារ (ក្នុងឃុំភាគច្រើនដែលអង្គការធ្វើការ)។ អង្គការបានផ្ដល់ម្ហូបអាហាររយៈពេល ២ ខែ ប្រដាប់ចម្រោះទឹក មុង និងរបស់ចាំបាច់ដទៃទៀត ដល់ប្រជាជន ៣០ ០០០ គ្រួសារ ក្នុងខេត្តចំនួន ២។ អង្គការបានធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងអង្គការ UNICEF អង្គការក្រៅរដ្ឋាភិបាលដទៃទៀត និងមន្ទីរគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ព្រមទាំងគណៈកម្មាធិការឃុំ និងស្រុក ដើម្បីសម្របសម្រួលការចែកអំណោយ។

ឥឡូវនេះ អង្គការបានប្ដូរទៅដំណាក់កាលស្ដារឡើងវិញ ដែលនឹងមានរយៈពេលរហូតដល់ ១ ឆ្នាំ និងចំណាយប្រាក់ប្រហែល ២៥០ ០០០ ដុល្លារអាមេរិក។ ទន្ទឹមនឹងនេះ លោក ហេង សុខ អ្នកឯកទេសកាត់បន្ថយគ្រោះមហន្តរាយរបស់អង្គការ Plan បានថ្លែងថា៖ «យើងកំពុងខិតខំធ្វើការដើម្បីធានាថា ទឹកជំនន់មិនប៉ះពាល់ដល់ការងារដែលយើងបានធ្វើចាប់តាំងពីឆ្នាំ២០០២ មក»។ កម្មវិធីកាត់បន្ថយគ្រោះមហន្តរាយ ដែលអង្គការបានចាប់ផ្ដើមក្នុងស្រុកចំនួន ៦ នៃខេត្តដែលអង្គការមានសកម្មភាព គឺខេត្តកំពង់ចាម និងខេត្តសៀមរាប មិនអាចទប់នឹងទំហំនៃគ្រោះទឹកជំនន់ឆ្នាំនេះឡើយ។

វិស័យ៣ ដែលអង្គការ Plan បានកំណត់ជាអាទិភាព ដើម្បីស្ដារឡើងវិញ គឺវិស័យអប់រំ ទឹក អនាម័យ និងមុខរបរចិញ្ចឹមជីវិត។ លោក Supriyanto បានថ្លែងថា៖ «យើងព្រួយបារម្ភណាស់អំពីលទ្ធភាពនៃករណីកង្វះអាហារូបត្ថម្ភកើនឡើង ក្នុងចំណោមកុមារ»។ ប្រជាជនកម្ពុជាតាមជនបទពឹងផ្អែកលើផលដំណាំឬស្រូវមួយដងក្នុងមួយឆ្នាំ ដែលភាគច្រើនត្រូវបានបំផ្លិចបំផ្លាញ ក្នុងឃុំនានាដែលទឹកជន់លិច។

លោក ហេង សុខ បានពន្យល់ថា សកម្មភាពកំពុងអនុវត្ត ដើម្បីចែកចាយពូជស្រូវ ដែលអនុញ្ញាតឲ្យមានការប្រមូលផលឆាប់រហ័ស ប៉ុន្តែកសិករនៅតំបន់រងគ្រោះទឹកជំនន់ខ្វះបទពិសោធក្នុងការធ្វើស្រែរយៈពេលខ្លី។ កសិករអាចរង់ចាំរហូតទាល់មួយឆ្នាំចាប់ពីខែធ្នូនេះ មុនពេលពួកគេមានដំណាំស្រូវម្ដងទៀត។

> សាលារៀនចំនួន ៦០កំពុងតែជន់លិច...

អ្នកស្រី ពេជ្រ សុផារី បានថ្លែងថា៖ «ពួកគេគ្មានសល់អ្វីទេ។ ពួកគេគ្មានអាហារទេ»។

អណ្ដូងក៏មានទឹកជំនន់ពេញ ដែលមិនអាចផឹកបានទេ។ មុនទឹកជំនន់ លទ្ធភាពប្រើទឹកដែលមានសុវត្ថិភាពក្នុងស្រុកនានា ដែលអង្គការ Plan ធ្វើការ គឺមានជាង ៤០ ភាគរយ។ អ្នកស្រី ពេជ្រ សុផារី បានបន្ថែមថា អណ្ដូង ១ភាគ៣ ត្រូវបានបំផ្លាញ ឬទឹកជន់លិច។

តម្រូវការលើការថែទាំសុខភាពក៏សំខាន់ផងដែរ។ លោក ម៉ាក មុនិត អ្នកគ្រប់គ្រងកម្មវិធីប្រចាំខេត្តកំពង់ចាម នៃអង្គការ Plan បានថ្លែងថា មានវេជ្ជបណ្ឌិតតែ៨នាក់ប៉ុណ្ណោះនៅមជ្ឈមណ្ឌលសុខភាពក្នុងខេត្ត។ លោកបានបន្តថា៖ «វេជ្ជបណ្ឌិតជាប់រវល់ណាស់។ ពីមុន ពួកគេអាចទៅពិនិត្យអ្នកជំងឺ ឥឡូវនេះ អ្នកជំងឺមកជួបពួកគេវិញ»។ លោកបានឲ្យដឹងទៀតថា រោគរាករូស គ្រុនចាញ់ គ្រុនក្ដៅ និងផ្ដាសាយ ជាជំងឺកើតឡើងជាទូទៅបំផុត។

កង្វះម្ហូបអាហារ សាលារៀនលិចទឹក និងតម្រូវការកសាងភូមិឡើងវិញបង្កការលំបាកថែមទៀតដល់អង្គការ Plan ក្នុងការបន្តសកម្មភាពរបស់ខ្លួនពន្យល់មាតាបិតាឲ្យយកកូនរបស់ពួកគេបន្តទៅសាលារៀន។ សាលាចំនួន៦០ កំពុងតែជន់លិចនៅឡើយ ក្នុងខេត្តសៀមរាប។ អ្នកស្រី ពេជ្រ សុផារី បានបន្តថា សៀវភៅ និងសម្ភារអប់រំក៏ត្រូវបានបំផ្លាញផងដែរ។ អ្នកស្រីបានបន្តថា៖ «គ្រូព្យាយាមជួយសង្គ្រោះសៀវភៅ និងសម្ភារទាំងនោះ ដោយដាក់វាលើធ្នើរ ប៉ុន្តែទឹកជំនន់ឡើងខ្ពស់ជាងធ្នើរទៅទៀត»។

លោក Supriyanto បានបន្តថា៖ «ប្រសិនបើយើងមិនអាចឲ្យកុមារវិលត្រឡប់ទៅសាលារៀនឲ្យបានឆាប់នោះទេ មាតាបិតាអាចនឹងប្រាប់កុមារទាំងនោះឲ្យនៅផ្ទះ និងជួយគ្រួសារ។ ក្នុងករណីដទៃទៀត មាតាបិតាទុកឲ្យពួកគេរកការងារដោយខ្លួនឯង ដើម្បីអាចរកបានប្រាក់យកមកកសាងឡើងវិញ។ ក្នុងករណីខ្លះ គ្មានអ្នកណាមើលថែពួកគេទេ។ យើងត្រូវប្ដូរទៅដំណាក់កាលនៃការស្ដារឡើងវិញឲ្យបានរហ័ស»៕ TK

# របាយការណ៍ទាក់ទងនឹងស្ថានភាពទឹកជំនន់

**របាយការណ៍ចេញផ្សាយដោយអង្គការសហប្រជាជាតិកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១**

### អាទិភាពចម្បងៗ

- មូលនិធិឆ្លើយតបបន្ទាន់របស់អង្គការសហប្រជាជាតិ ( UN's Central Emergency Respone Fund ) បានអនុម័តទឹកប្រាក់សរុប ៤លានដុល្លារសហរដ្ឋអាមេរិក
- UNDMT បន្តជួបជាមួយ NCDM ជាប្រចាំ

### ស្ថានភាពទូទៅ

តួលេខកាលពីថ្ងៃទី១៨ ខែតុលា របស់ NCDM បង្ហាញថា៖

- ខេត្តចំនួន១៨ នៅក្នុងចំណោមខេត្តទាំង២៤ នៅក្នុងប្រទេសកម្ពុជា បានទទួលរងផលប៉ះពាល់ដោយទឹកជំនន់ ក្នុងនោះខេត្តកណ្ដាល កំពង់ធំ ព្រៃវែង កំពង់ចាម បានទទួលរងគ្រោះយ៉ាងខ្លាំងជាងគេ។
- ប្រជាពលរដ្ឋចំនួន ៣៣១ ៧៦៥ គ្រួសារ( ជាង ១,៥លាននាក់ ) បានទទួលរងផលប៉ះពាល់ ហើយពលរដ្ឋចំនួន៤៦ ៤០៣ គ្រួសារបានជម្លៀសចេញ។
- មនុស្សចំនួន ២៤៧នាក់បានស្លាប់ និង ២០នាក់ទៀតបានរងរបួសដោយសារតែទឹកជំនន់។
- ដំណាំស្រូវចំនួន ៤០៥ ៦៨៦ ហិកតា បានទទួលរងផលប៉ះពាល់ ក្នុងនោះ ២៣២ ៣៧៧ ហិកតាត្រូវបានរាយការណ៍មកថា ខូចខាត ( ផ្ទៃដីដាំស្រូវសរុប ២ ៤៦៦ ៤២៩ហិកតា ដូច្នេះ ផ្ទៃដីស្រែខូចខាតដោយសារទឹកជំនន់ ស្មើនឹង ៩,៤ភាគរយនៃផ្ទៃដីសរុប )។

### តម្រូវការ និងការឆ្លើយតបរបស់មនុស្សធម៌

### ស្បៀងអាហារ

- ជាផ្នែកមួយនៃប្រតិបត្តិការឆ្លើយតបជាបន្ទាន់របស់ WFP ការចែកស្បៀងអាហារ បានចាប់ផ្ដើមឡើងតាមរយៈអង្គការក្រៅរដ្ឋាភិបាលកាលពីសប្ដាហ៍មុន ( មានអង្គការសង្គ្រោះកុមារ អង្គការការីតាស អង្គការ Church World Service អង្គការ ADRA និងអង្គការ CARE )។ ប្រជាជនទទួលរងគ្រោះដោយទឹកជំនន់ប្រហែល ១២ ០០០ គ្រួសារនៅខេត្តកំពង់ចាម កំពង់ធំ ព្រៃវែង ក្រចេះ និងកណ្ដាល នឹងទទួលបានអង្ករ ៥០គីឡូក្រាមមួយគ្រួសារ។
- លើសពីនេះទៅទៀត អង្គការ WFP កំពុងរៀបចំប្រតិបត្តិការបន្ទាន់ដ៏ធំមួយ ដើម្បីបំពេញតម្រូវការសង្គ្រោះ និងស្ដារឡើងវិញរបស់គ្រួសារទទួលរងគ្រោះខ្លាំងបំផុតនៅក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ។

### សុខភាព

- ក្រសួងសុខាភិបាល តាមរយៈមជ្ឈមណ្ឌលកម្ចាត់ជំងឺគ្រុនចាញ់របស់ខ្លួន មានផែនការចែកមុងដល់គ្រួសាររងគ្រោះដោយទឹកជំនន់នៅខេត្តស្ទឹងត្រែង។ ពួកគេបញ្ជាក់ថា មុងគួរតែចែកដល់គ្រួសារទាំងអស់នៅត្រឹមថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១១។
- ក្រសួងសុខាភិបាល/អង្គការសុខភាពពិភពលោក បានធ្វើការវាយតម្លៃតាមមណ្ឌលសុខភាពនានានៅខេត្តចំនួន ៨ មានខេត្តកណ្ដាល កំពង់ចាម ព្រៃវែង កំពង់ធំ សៀមរាប ព្រះវិហារ កំពង់ឆ្នាំង និងបាត់ដំបង ( ក្រចេះ និងស្ទឹងត្រែង កំពុងធ្វើនៅសប្ដាហ៍នេះ )។ នៅក្នុងខេត្តទាំង ៨ ក្រសួងសុខាភិបាល បានរាយការណ៍ថា មណ្ឌលសុខភាពចំនួន ១០៨កន្លែង ត្រូវបានទឹកជន់លិច ប៉ុន្ដែ សេវាសុខាភិបាល កំពុងត្រូវបានគេផ្ដល់ជូន។
- ការវាយតម្លៃនេះ បានសម្លឹងមើលលើសកម្មភាព៤កម្រិត មានសេវាសម្ភព ការចាក់ថ្នាំបង្ការ ការផ្ដល់ថ្នាំសម្រាប់អ្នកជំងឺរបេង ( ការព្យាបាលរយៈពេលខ្លីតាមរយៈការតាមដានដោយផ្ទាល់ ) និងថ្នាំប្រឆាំងជំងឺឱកាសនិយមសម្រាប់អ្នកជំងឺ HIV។ សេវាទាំងអស់នេះ កំពុងត្រូវបានគេផ្ដល់ជូននៅឡើយ។ ទីណាមណ្ឌលសុខភាពបិទទ្វារ គឺបុគ្គលិកពេទ្យចុះបម្រើការសេវាទាំងនេះនៅមូលដ្ឋានផ្ទាល់តែម្ដង។
- ក្រសួងសុខាភិបាល និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ( CDC ) ក៏កំពុងតែធ្វើការវិភាគប្រចាំថ្ងៃអំពីការផ្ទុះឡើងនូវបញ្ហាទាំងនោះ ដូចនៅថ្ងៃទី២៥ ខែតុលា ពុំមានរបាយការណ៍ធ្វើឡើងដោយ CDC និយាយស្ដីពីបញ្ហានេះឡើយ។
- អង្គការសុខភាពពិភពលោក បានរៀបចំកិច្ចប្រជុំពិភាក្សាមួយជាមួយនឹងបណ្ដាអង្គការមិនមែនរដ្ឋាភិបាលនានាដែលធ្វើការងារខាងសុខាភិបាល និងក្រសួងសុខាភិបាលកាលពីថ្ងៃទី០១ ខែវិច្ឆិកាថ្មីៗនេះ។

### ការការពារកុមារ

- កិច្ចប្រជុំជាមួយដៃគូដែលធ្វើការខាងការការពារកុមារនៅអំឡុងពេលទឹកជំនន់នេះ ត្រូវបានរៀបចំធ្វើឡើងកាលពីថ្ងៃម្សិលមិញ។ អ្នកចូលរួមមកពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ អង្គការ Save the Children អង្គការ World Vision និងអង្គការ Friends International បានឯកភាពគ្នាធ្វើការវាយតម្លៃលើការការពារកុមារនៅក្នុងខេត្តកណ្ដាល កំពង់ចាម សៀមរាប និងខេត្តកំពង់ធំ ដែលនឹងប្រព្រឹត្តទៅនៅសប្ដាហ៍ក្រោយ។ អង្គការ World Vision និង Save the Children បានបង្កើតមណ្ឌលកុមារមេត្រីចំនួន៤ នៅតំបន់មានសុវត្ថិភាពជាមួយនឹងសមត្ថភាពផ្ដល់ជម្រកដល់កុមារយ៉ាងតិច ១០០ នាក់។ ទោះជាយ៉ាងណា តម្រូវការនៅតែមានទំហំធំធេង និងមានតម្រូវការពង្រីកការអន្ដរាគមន៍ពាក់ព័ន្ធនឹងការការពារកុមារ។ បញ្ហាការការពារកុមារសំខាន់ៗ មាន៖
- ស្ថានភាពរស់នៅគ្មានផ្ទះសម្បែង និងភៀសខ្លួនរបស់ក្រុមគ្រួសាររួមទាំងកូនៗទៅកាន់តំបន់ដទៃដែលបង្កើនឲ្យមានហានិភ័យងាយប្រឈមមុខនឹងការបង្ក្រាប និងឃុំខ្លួនដោយខុសច្បាប់ផ្អែកតាមគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព។
- កុមារងាយប្រឈមមុខនឹងគ្រោះថ្នាក់លង់ទឹក។
- កុមារអាចត្រូវបានបំបែកចេញពីគ្រួសាររបស់ពួកគេ។
- តំបន់រងទឹកជំនន់ខ្លះ មិនងាយស្រួលធ្វើដំណើរទៅដល់ ហើយតំបន់សុវត្ថិភាពតែងតែមានលក្ខណៈតូចចង្អៀតមិនគ្រប់គ្រាន់សម្រាប់បង្កើតមណ្ឌលកុមារមេត្រី។
- គ្មានផែនការជម្លៀសខ្លួនត្រឹមត្រូវសម្រាប់កុមារកំព្រា ដែលសព្វថ្ងៃនេះស្ថិតនៅក្រោមទឹកជំនន់ ហើយកុមារទាំងឡាយដែលត្រូវបានគេជម្លៀសចេញ តែងតែមិនត្រូវបានគេចុះឈ្មោះ ឬផ្លាស់ប្ដូរដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន៕

DT ■



# កិច្ចសហប្រតិបត្តិការមានសារៈសំខាន់ណាស់ដើម្បីជួយកុមារដែលរងផលប៉ះពាល់ពីទឹកជំនន់

Jasmine Whitbread

***នាយកប្រតិបត្តិនៃអង្គការ** Save the Children International*



Jasmine Whitbread ( **ទីបីពីខាងស្តាំ** ) **នាយកប្រតិបត្តិនៃអង្គការ** Save the Children International **ចែកអំណោយទៅដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់។** រូបថត សហការី

កុមារប្រមាណ ៨០ ម៉ឺននាក់បានរងផលប៉ះពាល់ដោយសារគ្រោះទឹកជំនន់កាលពីពេលថ្មីៗនេះនៅប្រទេសកម្ពុជា ជាគ្រោះមហន្តរាយបរិស្ថានអាក្រក់បំផុតមិនធ្លាប់ជួបប្រទះក្នុងប្រទេសនេះក្នុងរយៈពេលជាងមួយទសវត្សរ៍នេះ។ ប្រជាជនដែលរងផលប៉ះពាល់សរុបមាន១,៦ លាននាក់ ប៉ុន្តែកុមារមានភាពងាយរងគ្រោះបំផុតក្នុងគ្រាអាសន្ននេះ ខណៈគ្រួសាររបស់ពួកគេតស៊ូសម្របខ្លួនទៅនឹងការបាត់បង់ផ្ទះសម្បែង ផលដំណាំ និងមុខរបរចិញ្ចឹមជីវិត ហើយក្នុងករណីខ្លះទៀតបាត់បង់សមាជិកគ្រួសារជាទីស្រឡាញ់របស់ពួកគេថែមទៀត។

កុមាររងគ្រោះដោយសារទឹកជំនន់និងក្រុមគ្រួសាររបស់ពួកគេបច្ចុប្បន្នប្រឈមនឹងហានិភ័យធ្ងន់ធ្ងរ ដោយសារមណ្ឌលសុខភាពរាប់រយកន្លែងមិនអាចប្រើប្រាស់បាន ហើយសាលារៀនជាងមួយពាន់កន្លែងត្រូវបិទទ្វារ។ ជារៀងរាល់ថ្ងៃ កុមារម្នាក់មិនបានទៅសាលារៀនបង្កើនហានិភ័យកុមារបោះបង់ចោលការសិក្សានៅក្នុងរយៈពេលយូរ។ កាន់តែអាក្រក់ជាងនេះថែមទៀតនៅពេលទឹកជំនន់ចាប់ផ្តើមស្រក ទឹកថ្លុករួមផ្សំនឹងកង្វះអនាម័យអាចនឹងបណ្តាលឲ្យជំងឺដែលកុមារមានភាពងាយរងគ្រោះជាពិសេសនោះកាន់តែឆ្លងរាលដាលខ្លាំងឡើង ហើយភាពក្រីក្រ និងការបាត់បង់ប្រាក់ចំណូលគ្រួសារកាន់តែច្រើនក៏អាចនឹងបង្ខំកុមារឲ្យចេញទៅធ្វើការងារដើម្បីជួយគ្រួសាររបស់ពួកគេ ដោយមិនគ្រាន់តែធ្វើឲ្យពួកគេគេចវេះពីការសិក្សាប៉ុណ្ណោះទេ តែក៏ធ្វើឲ្យពួកគេប្រឈមហានិភ័យនៃការកេងប្រវ័ញ្ច និងជួញដូរផងដែរ។

ការខូចខាតហេដ្ឋារចនាសម្ព័ន្ធដទៃទៀតដោយសារទឹកជំនន់បច្ចុប្បន្ននៅពុំទាន់ដឹងនៅឡើយទេ។ អ្វីដែលយើងបានដឹងគឺថា វានឹងត្រូវការពេលវេលានិងធនធានយ៉ាងច្រើនដើម្បីធ្វើឲ្យហេដ្ឋារចនាសម្ព័ន្ធទាំងនេះវិលត្រឡប់មករកភាពប្រក្រតីវិញ។ ទន្ទឹមនឹងនេះដែរ វាក៏សំខាន់ផងដែរក្នុងការស្វែងរកនូវវិធីសាស្ត្រផ្សេងប្រកបដោយភាពច្នៃប្រឌិត ដោយកសាងកិច្ចសហប្រតិបត្តិការដើម្បីលើកឡើងអំពីសេចក្តីត្រូវការ និងកាត់បន្ថយហានិភ័យដែលកុមារកំពុងប្រឈម។

ការងារនេះអាចសម្រេចបានប្រកបដោយប្រសិទ្ធភាពក្នុងករណីមានការបន្តបង្កើនការជួយគាំទ្រ និងកិច្ចសហប្រតិបត្តិការរវាងអង្គការមិនមែនរដ្ឋាភិបាល អង្គការសហប្រជាជាតិ រដ្ឋាភិបាល និងម្ចាស់ជំនួយដែលយើងធ្លាប់មើលឃើញកន្លងមកតែប៉ុណ្ណោះ។ តាមរយៈការធ្វើការងាររួមគ្នា ការប្រមូលធនធានរបស់យើង និងការចែករំលែកព័ត៌មានសំខាន់ៗរួមគ្នា យើងនឹងអាចដោះស្រាយបាននូវឧបសគ្គនានាដែលនៅនឹងមុខយើង។

ដោយសារតែកិច្ចសហប្រតិបត្តិការយ៉ាងស្អិតល្មួតនេះ អង្គការ Save the Children អាចចុះធ្វើការចែកស្បៀងនិងសម្ភារសំខាន់ៗដទៃទៀតទៅដល់ពលរដ្ឋចំនួន ៣៣ ៧០០ នាក់នៅក្នុងខេត្តកំពង់ចាម និងព្រៃវែង។ ការចែកនេះអាចសម្រេចទៅបានដោយសារតែមានការជួយឧបត្ថម្ភហិរញ្ញវត្ថុពីសមាជិករបស់យើង USAID និងអំណោយស្បៀងពីកម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ។

លើសពីនេះទៀត អង្គការ Save the Children បានបង្កើតសាលារៀនបណ្តោះអាសន្នជាង ៣០០ កន្លែង និងកំពុងបន្តបង្កើតថែមទៀតនៅតាមអគារសហគមន៍ និងផ្ទះរបស់អ្នកភូមិដទៃទៀត ដោយដំណើរការបង្ហាត់បង្រៀនដោយលោកគ្រូ អ្នកគ្រូដែលបច្ចុប្បន្នមិនអាចធ្វើដំណើរទៅដល់សាលារៀនដែលរងគ្រោះដោយសារទឹកជំនន់ ឬត្រូវបានបំផ្លិចបំផ្លាញរបស់ពួកគេ។ សមិទ្ធផលទាំងនេះ គឺជាលទ្ធផលនៃភាពជាដៃគូរបស់យើងជាមួយក្រសួងអប់រំ យុវជន និងកីឡា និងដៃគូរបស់ពួកគេនៅតាមបណ្តាខេត្តដែលធ្វើឲ្យកុមារជាងមួយម៉ឺននាក់បានវិលត្រឡប់ទៅរៀនសូត្រវិញ។ តាមរយៈការធ្វើបែបនេះ យើងមិនគ្រាន់តែកំពុងជួយការរៀនសូត្ររបស់កុមារទេ តែយើងក៏កំពុងជួយស្តារឡើងវិញនូវអារម្មណ៍ប្រក្រតីមួយចំនួនក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេផងដែរ ខណៈកំពុងជួយឪពុកម្តាយរបស់ពួកគេផ្តោតទៅលើការជម្នះឧបសគ្គនានានៅចំពោះមុខពួកគេ។

ការងើបឡើងវិញពីគ្រោះមហន្តរាយក្នុងទំហំធំនេះនឹងត្រូវការពេលវេលា ហើយប្រសិទ្ធភាពនឹងត្រូវគេឃើញចាប់ផ្តើមមានក្នុងរយៈពេលយូរក្រោយដីស្រែចម្ការលែងជន់លិច។ ដំណោះស្រាយដែលត្រូវការចំណាយតិចតែមានភាពច្នៃប្រឌិតអាចផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋក្នុងទំហំធំ។ អង្គការ Save the Children កំពុងសម្លឹងទៅរកការបន្តពង្រឹងកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អង្គការសហប្រជាជាតិ និងសហគមន៍ម្ចាស់ជំនួយដើម្បីរួមគ្នាកាត់បន្ថយហានិភ័យ និងធ្វើឲ្យរឹតតែប្រសើរឡើងនូវអនាគតដ៏ល្អមួយសម្រាប់កុមារដែលរងគ្រោះដោយសារទឹកជំនន់ និងក្រុមគ្រួសាររបស់ពួកគេ។ នេះ គឺជាវិធីតែមួយគត់ដើម្បីឆ្ពោះទៅមុខបន្តទៀត៕ CR ■

> " កុមាររងគ្រោះដោយសារទឹកជំនន់និងក្រុមគ្រួសាររបស់ពួកគេបច្ចុប្បន្នប្រឈមនឹងហានិភ័យធ្ងន់ធ្ងរ ដោយសារមណ្ឌលសុខភាពរាប់រយកន្លែងមិនអាចប្រើប្រាស់បាន ហើយសាលារៀនជាងមួយពាន់កន្លែងត្រូវបិទទ្វារ។ ជារៀងរាល់ថ្ងៃ....



ក្មេងៗទាំងនេះដែលប៉ះពាល់ដោយទឹកជំនន់នៅកំពង់ចាម កំពុងទទួលបាននូវការអប់រំនៅសាលារៀនបណ្តោះអាសន្នដែលបង្កើតឡើងដោយអង្គការ Save the Children។

**សេចក្តីរាយការណ៍ពិសេសរបស់កាសែត ភ្នំពេញ ប៉ុស្តិ៍ទាក់ទងនឹងសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាល គឺមានចេញផ្សាយជារៀងរាល់ខែ។**

**បើលោកអ្នក ឬអង្គការក្រៅរដ្ឋាភិបាលណាមួយមានចំណាប់អារម្មណ៍ សូមទាក់ទង**: vincent.macisaac@phnompenhpost.com ឬ rith.sam@phnompenhpost.com

# ការរៀបចំសម្រាប់ទឹកជំនន់ និងគ្រោះមហន្តរាយក្នុងតំបន់តិចពេក ឬយឺតពេក មែនទេ?

Mely Caballero-Anthony និង Sofiah Jamil

ភ្លៀងធ្លាក់យ៉ាងធ្ងន់ធ្ងរនៅក្នុងប្រទេសកម្ពុជា និងថៃចាប់តាំងពីខែកក្កដា ឆ្នាំ២០១១ មកបានបណ្តាលឲ្យខាតបង់សេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរបង្កមកពីការខូចខាតដោយសារទឹកជំនន់ និងបានឆក់យកអាយុជីវិតមនុស្សយ៉ាងហោចណាស់ ៥០០នាក់។ សម្រាប់ប្រទេសថៃដែលមានកន្លែងខ្លះមានកម្ពស់តែ ២ ម៉ែត្រប៉ុណ្ណោះខ្ពស់ជាងនីវ៉ូទឹកសមុទ្រ ទឹកជំនន់ត្រូវគេអះអាងថាជាគ្រោះមហន្តរាយទឹកជំនន់អាក្រក់បំផុតនៅក្នុងប្រទេសនេះក្នុងរយៈពេល ៥០ ឆ្នាំចុងក្រោយ ជាមួយនឹងខេត្តចំនួនមួយភាគបីរបស់ខ្លួនបានប្រកាសជាតំបន់ជួបគ្រោះមហន្តរាយ។ យ៉ាងណាក្តីឧបទ្ទវហេតុបែបនេះពុំមែនជាអ្វីដែលថ្មីហើយក៏មិនមែនជាអ្វីដែលគេមិនបានរំពឹងទុកនោះទេ ដោយសារមូលហេតុធំៗចំនួនពីរ៖

ទី ១ ការសិក្សាផ្សេងៗ បានបង្ហាញអំពីការកើនឡើងនូវភាពងាយប្រឈមនៃបណ្តាប្រទេសតំបន់អាស៊ីអាគ្នេយ៍ទៅនឹងគ្រោះមហន្តរាយបង្កមកពីអាកាសធាតុ។ ក្នុងចំណោមការសិក្សាទាំងនោះមានរបាយការណ៍ពីមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ ( IDRC ) ដែលបានបង្ហាញពីតំបន់ជាច្រើននៅអាស៊ីអាគ្នេយ៍ដែលមានភាពងាយប្រឈមខ្ពស់ទៅនឹងគ្រោះថ្នាក់បរិស្ថានផ្សេងៗ។ ដូចគ្នានេះដែរ របាយការណ៍ជាច្រើនផ្សេងទៀតមានជាអាទិ៍របស់ធនាគារពិភពលោក អង្គការសហប្រជាជាតិ និងមូលនិធិទូទាំងពិភពលោកបានបង្ហាញពីកត្តាសេដ្ឋកិច្ចសង្គមដែលជំរុញឲ្យកើនឡើងនូវភាពងាយប្រឈមមានដូចជាការកើនឡើងនៃចំនួនប្រជាជននៅក្នុងបណ្តាក្រុងនានា។ ទី ២ វាមានចំណេះដឹង និងដំណោះស្រាយស្រាប់ដើម្បីគ្រប់គ្រងគ្រោះមហន្តរាយទឹកជំនន់ ដោយផ្អែកទៅលើបទពិសោធជាយូររបស់តំបន់នេះជាមួយគ្រោះមហន្តរាយនានា។ កត្តាទាំងនេះសំខាន់ជាពិសេសនៅតំបន់អាស៊ីអាគ្នេយ៍ដែលមានទីក្រុងធំៗយ៉ាងតិចចំនួន ៣ គឺបាងកក ហ្សាការតា និងម៉ានីល។

**និចលភាព និងប្រភពរបស់វា**

ទោះបីជាមានព័ត៌មានបែបនេះក្តី វានៅតែមានកម្រិតនិចលភាពខ្លាំងនៅតាមបណ្តារដ្ឋនានាដើម្បីសមាហរណកម្មយុទ្ធសាស្ត្រផ្សាំទៅនឹងការប្រែប្រួលអាកាសធាតុជាមួយនឹងការត្រៀមខ្លួនទទួលគ្រោះមហន្តរាយ។ ការផ្សាំទៅនឹងការប្រែប្រួលអាកាសធាតុសំដៅលើការឆ្លើយតបដើម្បីកាត់បន្ថយភាពងាយប្រឈមទៅនឹងផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុ។ គឺវាមានសារៈសំខាន់ជាពិសេសសម្រាប់តំបន់ងាយជួបនឹងគ្រោះមហន្តរាយ ព្រោះវាមិនគ្រាន់តែជួយបង្កើនកម្រិតនៃការត្រៀមខ្លួនរបស់សហគមន៍ប៉ុណ្ណោះទេ តែក៏ភាពឆាប់ស៊ាំនឹងការកើនឡើងចំនួន និងទំហំនៃគ្រោះមហន្តរាយផងដែរ។ ដូច្នេះ វាសំខាន់ត្រូវយល់ពីមូលហេតុដែលមាននិចលភាពនេះ ដែលវាភាគច្រើនអាចត្រូវលុបបំបាត់បានតាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការ និងសហការនៅថ្នាក់តំបន់។

កត្តាចម្បងបណ្តាលឲ្យមាននិចលភាពក្នុងការសមាហរណកម្មយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុទៅក្នុងការត្រៀមខ្លួនទទួលគ្រោះមហន្តរាយជានិច្ចកាលជាការងារសម្របសម្រួលយ៉ាងស្មុគស្មាញនៅគ្រប់ភ្នាក់ងារ និងស្ថាប័នពាក់ព័ន្ធជាច្រើន។

បញ្ហាការប្រែប្រួលអាកាសធាតុមានទំហំធំជាងបញ្ហាបរិស្ថាន ហើយត្រូវការឲ្យមានការផ្លាស់ប្តូរ និងការរួមចំណែកពីវិស័យផ្សេងៗពាក់ព័ន្ធនឹងសេដ្ឋកិច្ច។ សម្រាប់ការគ្រប់គ្រងទឹកជំនន់ បញ្ហានេះថែមទាំងគ្របដណ្តប់បញ្ហានានាដូចជាការគ្រប់គ្រងកាកសំណល់ ប្រព័ន្ធធារាសាស្ត្រ និងបរិមាណនៃការបូមទឹកនៅក្នុងដី និងនគរូបនីយកម្មផងដែរ។

ជាឧទាហរណ៍ ការរុះរើទីលំនៅសហគមន៍ពលរដ្ឋក្រីក្រនៅតាមទីក្រុងដែលរស់នៅក្នុងតំបន់ងាយប្រឈមនឹងទឹកជំនន់តម្រូវនូវធនធាន និងពេលវេលាច្រើន។ ការយកចិត្តទុកដាក់រួមមានការធានាថា លំនៅដ្ឋាន និងជីវភាពរស់នៅកន្លែងថ្មីស្ថិតនៅក្បែរប្រភពមុខរបរសេដ្ឋកិច្ច។ ដូច្នេះ ការប៉ះប៉ូវប្រព័ន្ធទាំងនេះសម្រាប់រយៈពេលមធ្យម និងរយៈពេលយូរជានិច្ចកាលមិនមែនជាការចាប់អារម្មណ៍របស់អ្នកធ្វើគោលនយោបាយដែលមានអាណត្តិក្នុងមុខតំណែងជាធម្មតាពី ៣ ទៅ ៥ ឆ្នាំឡើយ។

**ការសម្របខ្លួន និងការសម្រាល**

កត្តាទី ២ នាំឲ្យមាននិចលភាព គឺការផ្តល់សារៈសំខាន់យឺតពេលវេលាដល់ការផ្សាំនឹងការប្រែប្រួលអាកាសធាតុបើធៀបនឹងការសម្រាលការប្រែប្រួលអាកាសធាតុ។ ខណៈការសម្រាលការប្រែប្រួលអាកាសធាតុសំដៅសំខាន់ទៅលើការកាត់បន្ថយការបញ្ចេញកាបូនដែលជាប្រភពនាំឲ្យមានការប្រែប្រួលអាកាសធាតុ វាពុំបានជួយទប់ស្កាត់ផលប៉ះពាល់ដែលមានស្រាប់នៃការប្រែប្រួលអាកាសធាតុទេ។

ដូច្នេះ បញ្ហានេះត្រូវការជាចាំបាច់នូវវិធានការឲ្យមានការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។ ប្រទេសនានាបច្ចុប្បន្នត្រូវតែបំពេញពេលវេលាដែលបាត់បង់ ព្រោះពួកគេទើបតែខិតខំប្រឹងប្រែងកាលពីពេលថ្មីៗនេះដើម្បីវាស់ស្ទង់ និងគ្រប់គ្រងការបញ្ចេញកាបូនរបស់ពួកគេនៅមុនជំនួបកំពូលស្តីពីការប្រែប្រួលអាកាសធាតុធ្វើឡើងនៅទីក្រុងកូប៉ិនហាកកាលពីឆ្នាំ២០០៩ ប៉ុណ្ណោះ។

> វាមានសារៈសំខាន់ជាពិសេសសម្រាប់តំបន់ងាយជួបនឹងគ្រោះមហន្តរាយ ព្រោះវាមិនគ្រាន់តែជួយបង្កើនកម្រិតនៃការត្រៀមខ្លួនរបស់សហគមន៍ប៉ុណ្ណោះទេ តែក៏ភាពឆាប់ស៊ាំនឹងការកើនឡើង....



**ផ្ទះរបស់ប្រជាពលរដ្ឋជាច្រើនរយខ្នងនៅក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំងត្រូវបានទឹកជន់លិច។** រូបថត សំរិទ្ធ

ការកាត់បន្ថយការបញ្ចេញកាបូនក៏អនុញ្ញាតឲ្យអ្នកធ្វើគោលនយោបាយដឹកនាំការយកចិត្តទុកដាក់ទៅលើបញ្ហាពាក់ព័ន្ធនឹងការអភិវឌ្ឍដែលមានជាអាទិ៍សន្តិសុខថាមពល និងការបំពេញតាមសេចក្តីត្រូវការថាមពលដែលចេះតែកើនឡើងរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍ និងប្រទេសឧស្សាហកម្មនានា។ ខណៈបញ្ហាទាំងនេះសំខាន់ វាគ្របដណ្តប់លើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលសហគមន៍ជាច្រើននៅប្រទេសអាស៊ីអាគ្នេយ៍មានភាពងាយប្រឈមខ្ពស់។

នេះពាក់ព័ន្ធនឹងកត្តារួមចំណែកទី៣ នៃនិចលភាព គឺកំណើនសេដ្ឋកិច្ចជាអាទិភាព។ ទាក់ទងនឹងការបង្កើតការការពារគ្រោះទឹកជំនន់ ទីក្រុង ឬមជ្ឈមណ្ឌលប្រមូលផ្តុំសកម្មភាពសេដ្ឋកិច្ចធំៗផ្សេងទៀតជាកន្លែងដែលត្រូវការពារមុនគេ។ ទីក្រុងបាងកករងនូវការរិះគន់ម្តងម្កាលចំពោះបញ្ហានេះ ខណៈប្រព័ន្ធការពារទឹកជំនន់របស់រាជធានីនេះបង្កឲ្យមានការបង្វែរទឹកជំនន់ទៅកាន់តំបន់ដទៃទៀតនៃប្រទេសថៃមានជាអាទិ៍ក្រុងអយុធ្យាជាដើម។ នៅខណៈពេលដែលការការពារទីក្រុងធំមានសារៈសំខាន់ដើម្បីបង្ការកុំឲ្យមានការខាតបង់សេដ្ឋកិច្ចរាប់លានដុល្លារ វាពុំធានាការទប់ស្កាត់ដូចគ្នានេះសម្រាប់សហគមន៍នានាដែលងាយប្រឈមនឹងគ្រោះមហន្តរាយបំផុតនៅតាមតំបន់ទីក្រុងនោះទេ។

ការខាតបង់របស់ពួកគេពុំមែនគ្រាន់តែដល់សេដ្ឋកិច្ចទេ តែដល់ការរស់នៅ ដែលនោះ គឺការទទួលបានការផ្គត់ផ្គង់សំខាន់ៗដូចជា ស្បៀង ទឹក និងអគ្គិសនី។ ហេតុនេះ ការសិក្សាកាលពីពេលថ្មីៗនេះបានសង្កត់ធ្ងន់ពីតម្រូវការឲ្យមានការកសាងភាពឆាប់ងើបឡើងវិញទៅនឹងការប្រែប្រួលអាកាសធាតុនៅតាមបណ្តាក្រុងទំហំមធ្យមនានាដែលអាចពុំមានធនធានច្រើនដូចទីក្រុងធំៗទាំងនោះ។

**ការកាត់បន្ថយនិចលភាពតាមរយៈកិច្ចសហប្រតិបត្តិការថ្នាក់តំបន់:**

តើសារអ្វីអាចត្រូវគេទាញចេញពីភាពអសកម្មនៅក្នុងការធ្វើសមាហរណកម្មយុទ្ធសាស្ត្រនៃការប្រែប្រួលអាកាសធាតុទៅក្នុងការត្រៀមខ្លួនទទួលគ្រោះមហន្តរាយ? វាជាការពិតដែលថា អ្នកធ្វើគោលនយោបាយតែងតែទម្លាក់បញ្ហាទៅលើកង្វះសមត្ថភាព។ ខណៈនេះជាការពិតនៅក្នុងក្របខ័ណ្ឌជាតិ វាមានសារៈសំខាន់ដែលប្រទេសនានាត្រូវសហការគ្នាឆ្លងកាត់ព្រំដែនដើម្បីកសាងសមត្ថភាព។

ក្របខ័ណ្ឌថ្នាក់តំបន់នៅអាស៊ីអាគ្នេយ៍បច្ចុប្បន្នមានស្រាប់ ដែលខ្លះកំពុងដំណើរការមានដូចជាមជ្ឈមណ្ឌលសម្របសម្រួលសម្រាប់ជំនួយមនុស្សធម៌ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយក្រោមកិច្ចព្រមព្រៀងអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបបន្ទាន់ ( AADMER )។ ខណៈគំនិតផ្តួចផ្តើមបែបនេះត្រូវបានដំណើរការតាំងពីមានគ្រោះមហន្តរាយដូចជា ខ្យល់ព្យុះណាហ្គីសកាលពីឆ្នាំ២០០៨ ក្របខ័ណ្ឌការងារថ្នាក់តំបន់ត្រូវការការពង្រឹងបន្ថែមទៀតដើម្បីបង្កើនយន្តការត្រៀមខ្លួន និងសម្របខ្លួនឲ្យស្របទៅនឹងការប្រែប្រួលអាកាសធាតុច្រើនដើម្បីឆ្លើយតបឲ្យបានទាន់ពេលវេលាមានគ្រោះមហន្តរាយ។ ពាក់ព័ន្ធនឹងបញ្ហានេះ កិច្ចប្រឹងប្រែងរបស់អាស៊ានដើម្បីប្រៀបបញ្ចូល និងសមាហរណកម្មយុទ្ធសាស្ត្រទូលំទូលាយរបស់ខ្លួនអំពីសន្តិសុខស្បៀង និងថាមពលទៅនឹងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

លើសពីនេះទៀត កិច្ចសហប្រតិបត្តិការថ្នាក់តំបន់អាចជួយសម្រួលការផ្ទេរនូវការអនុវត្តល្អៗ។

ខណៈកិច្ចសហប្រតិបត្តិការក្នុងតំបន់នៅកម្រិតផ្លូវការមានសារៈសំខាន់ ការងារជាច្រើនអាចត្រូវបានធ្វើដើម្បីបង្កើនកម្រិតនៃកិច្ចសហប្រតិបត្តិការរវាងសង្គមស៊ីវិលអាស៊ាន និងសហគមន៍ពាណិជ្ជកម្ម។ អាស៊ានត្រូវតែបង្កើនការចូលរួមរបស់ខ្លួនជាមួយសហគមន៍ដើម្បីយល់ឲ្យកាន់តែប្រសើរថាតើការប្រែប្រួលអាកាសធាតុបន្ថែមពីលើគ្រោះមហន្តរាយបង្កឡើងដោយធម្មជាតិ និងមនុស្សដែលមានស្រាប់នឹងប៉ះពាល់ដល់សុវត្ថិភាពតំបន់យ៉ាងដូចម្តេច។ ការចូលរួមកាន់តែទូលំទូលាយជាមួយស្ថាប័នឯកជនដែលមានបំណងប្រាថ្នាចង់បានការទទួលខុសត្រូវសង្គមរួមគ្នាក៏នឹងបើកទ្វារចំហទទួលការជួយឧបត្ថម្ភត្រូវគោលដៅតាមគម្រោងនានាដែលអាចមិនទទួលបានការជួយគាំទ្រគ្រប់គ្រាន់ពីរដ្ឋាភិបាល។ វានៅតែត្រូវរង់ចាំមើលថាតើកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងការត្រៀមខ្លួនទទួលគ្រោះមហន្តរាយនៅអាស៊ីអាគ្នេយ៍នឹងវិវត្តយ៉ាងដូចម្តេច។ តើអាស៊ានអាចផ្លាស់ប្តូរពីការគ្រាន់តែប្រតិកម្មទៅនឹងគ្រោះមហន្តរាយទៅជាការបញ្ចេញសកម្មភាពជាមុនបន្ថែមទៀតនៅក្នុងការរៀបចំទទួលគ្រោះមហន្តរាយនេះដែរឬទេ? បន្ទាប់ពីមានគ្រោះកោលាហលធម្មជាតិបំផ្លិចបំផ្លាញជាច្រើនលើកមក បណ្តាប្រទេសអាស៊ានពុំគួររង់ចាំឲ្យមានខ្យល់ព្យុះណាហ្គីស ឬកេតសាណាផ្សេងទៀតបង្កឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរបែបនេះទៀតទេ។

**( លោក** Mely Caballero-Anthony **គឺសាស្ត្រាចារ្យរង និងជាប្រធាន ហើយលោក** Sofiah Jamil **គឺជាសមាជិកស្រាវជ្រាវនៅមជ្ឈមណ្ឌលសម្រាប់ការសិក្សាអំពីសន្តិសុខមិនមែនជាប្រពៃណីនៅមហាវិទ្យាល័យសិក្សាអន្តរជាតិ** S. Rajaratnam ( RSIS ) **នៃសាកលវិទ្យាល័យបច្ចេកវិទ្យាណាន់យ៉ាង។**ICR ■



ក្រុមគ្រួសារមួយនេះដែលមានកូនតូចៗ កំពុងតែរស់នៅក្នុងតង់នៃជំរំសម្រាប់ជនភៀសខ្លួនដោយសារទឹកជំនន់នៅខេត្តកំពង់ធំ។ រូបថត Nikki Majewski

# កម្ពុជា ក៏បានរងគ្រោះពីទឹកជំនន់ដ៏ធ្ងន់ធ្ងរដែរ

John Macgregor

អ្នកដែលមានបទពិសោធផ្ទាល់ក្នុងការផ្សាយអត្ថបទព័ត៌មាន តែងតែជួបបញ្ហាលំបាកក្នុងការទាក់ទង ពោលគឺអ្វីដែលពួកគេបានឃើញនៅក្នុងការផ្សាយ ទំនងជាអាចមានសភាពខុសប្លែកឆ្ងាយពីអ្វីដែលពួកគេជួបប្រទះដោយផ្ទាល់។

ក្នុងនាមជាបុគ្គលិកជំនួយម្នាក់ចំពោះគ្រោះមហន្តរាយទឹកជំនន់នាពេលបច្ចុប្បន្ននៅកម្ពុជា ខ្ញុំដឹងពីអារម្មណ៍បែបនេះយ៉ាងច្បាស់។

អំឡុងពេលថ្ងៃ ក្រុមការងារជនជាតិខ្មែរ និងរូបខ្ញុំ បានធ្វើដំណើរឆ្លងកាត់ស្រុកសង្កែនិងស្រុកមោងឫស្សី ខេត្តបាត់ដំបង។ ក្នុងការធ្វើដំណើររយៈពេល១ម៉ោងតាមកាណូតចាប់ពីទីទួលតូចមួយទៅកាន់ទីទួលមួយទៀត ដែលពោរពេញទៅដោយប្រជាពលរដ្ឋភៀសខ្លួនពីទឹកជំនន់រាប់ពាន់នាក់។ យើងនាំយកស្បៀងអាហារនិងទឹកស្អាតជូនដល់អ្នកគ្មានអាហារគ្រប់គ្រាន់ ព្រមទាំងក្រុមគ្រូពេទ្យ និងឱសថមួយចំនួនសម្រាប់អ្នកជំងឺផងដែរ។

នៅពេលល្ងាចខ្ញុំបានស្វែងរកព័ត៌មានផ្សេងៗតាមគេហទំព័រអន្តរជាតិ និងជាតិ ព្រមទាំងអានអត្ថបទរឿងរ៉ាវដ៏ច្រើនហួរហែស្តីពីទឹកជំនន់ក្នុងក្រុងបាងកក(ដែលមិនទាន់កើតឡើងធ្ងន់ធ្ងរនៅឡើយ)។ បន្តិចក្រោយមក មានកថាខណ្ឌមួយបានរៀបរាប់ពីប្រទេសកម្ពុជា នោះជាចំណុះគួរឲ្យចាប់អារម្មណ៍បំផុត។

សៀវភៅស្តីពីភូមិសាស្ត្រប្រទេសកម្ពុជាដ៏ល្បីក្នុងសង្គ្រាមឥណ្ឌូចិនរបស់ William Shawcross ត្រូវបានឲ្យឈ្មោះថា «ពិព័រណ៍ត្រួសៗ» (Slideshow)។ សៀវភៅស្តីពីភូមិសាស្ត្រកម្ពុជាក្នុងគ្រោះមហន្តរាយទឹកជំនន់ឥណ្ឌូចិននាពេលបច្ចុប្បន្ន អាចហៅបានថា «គួរហើយសឹមគិត»។

ប្រធានអង្គការសង្គ្រោះកុមារអន្តរជាតិ (Save the Children) ទើបបានធ្វើទស្សនកិច្ចតំបន់ឥណ្ឌូចិនដើម្បីស្វាបស្ទង់ពីគ្រោះមហន្តរាយទឹកជំនន់ ហើយលោកបានដាក់ប្រទេសកម្ពុជាស្ថិតក្នុងលំដាប់ទី១ ចំណោមបណ្តាប្រទេសដទៃនៅតំបន់នេះ ក្នុងលក្ខខណ្ឌចាំបាច់ជាងគេ។ ទិន្នន័យចុងក្រោយបំផុតបានប្រាប់យើងថា ប្រជាជនកម្ពុជាប្រមាណ ៥០ម៉ឺននាក់បង្ខំចិត្តជម្លៀសខ្លួនចេញពីលំនៅដ្ឋានទៅកាន់ទីទួលសុវត្ថិភាព។

> វាពិតជាលំបាកក្នុងការទប់ស្កាត់ជំងឺរាតត្បាតនានានៅតាមតំបន់ទាំងនេះ។ ពួកគេប្រឈមនឹងកម្តៅថ្ងៃ សំណើមគ្រប់ទីកន្លែង មនុស្សរស់នៅច្រើនកុះករ និងលាមកសត្វពាសពេញទឹក...

ពាក្យថា «ការភៀសខ្លួន» ស្តាប់ទៅមិនសមទំនងសោះ។ ដូចដែលយើងបានឃើញក្នុងខេត្តបាត់ដំបងនៅខែនេះ អ្វីដែលបានកើតឡើងជាក់ស្តែង គឺទឹកជំនន់ឡើងលិចផ្ទះសម្បែងរបស់ពួកគេ និងត្រូវតែរើចេញ រួមទាំងកុមារ សត្វគោក្របី ជ្រូក មាន់ ទា ឆ្កែ និងឆ្មាជាដើម ទៅកាន់ទីទួលសុវត្ថិភាពតូចៗ ជាពិសេសលើកំណាត់ផ្លូវលំខ្ពស់ៗ។ នៅទីនេះទឹកជន់លិចជាច្រើនសប្តាហ៍ ពួកគេរស់នៅក្នុងតង់កៅស៊ូលើភក់ប៉ប៉ិចប៉ប៉ាច់។

វាពិតជាលំបាកក្នុងការទប់ស្កាត់ជំងឺរាតត្បាតនានានៅតាមតំបន់ទាំងនេះ។ ពួកគេប្រឈមនឹងកម្តៅថ្ងៃ សំណើមគ្រប់ទីកន្លែង មនុស្សរស់នៅច្រើនកុះករ និងលាមកសត្វពាសពេញទឹក។ ជាក់ស្តែង កុមារភាគច្រើន បច្ចុប្បន្នកំពុងរងគ្រោះដោយសារជំងឺរាករូស។ ជំងឺរលាកសួត គ្រុនឈាម ប៉ារ៉ាស៊ីត គ្រុនក្តៅនិងរមាស់ គឺជារោគរាតត្បាតដែលកើតមានគ្រប់ទីកន្លែង។ វេជ្ជបណ្ឌិតរបស់លោក ២នាក់ បានព្យាបាលមនុស្ស១៧០០ នាក់ក្នុងមួយសប្តាហ៍។

«ការផ្តាច់ទំនាក់ទំនង» ក៏មានចំពោះរាជរដ្ឋាភិបាលនិងសង្គមស៊ីវិលផងដែរ។ អង្គការសុខភាពពិភពលោក (WHO) បានប្រកាសថា នឹងគ្មានផ្ទុះជំងឺរាតត្បាតទេ ហើយគណៈកម្មាធិកាគ្រប់គ្រងគ្រោះមហន្តរាយជាតិបានថ្លែងថា ប្រជាពលរដ្ឋដែលជម្លៀសខ្លួនច្រើនបំផុតនៅតំបន់ជាច្រើនក្នុងខេត្តកំពង់ឆ្នាំង និងកំពង់ធំ បានត្រឡប់ទៅកាន់លំនៅដ្ឋានវិញ។

នេះអាចជាព័ត៌មានចំពោះប្រជាពលរដ្ឋរាប់ពាន់នាក់ដែលរស់នៅក្នុងវាលភក់នៃស្រុកសង្កែ និងស្រុកមោងឫស្សី ខេត្តបាត់ដំបង ដោយយើងបានរកឃើញនូវជំងឺអាសន្នរោគកើតលើកុមារ ៤ករណី នៅឃុំតាគុន កាលពីថ្ងៃសុក្រកន្លងទៅ។

យើងបានទៅដល់តំបន់រងគ្រោះទាំងនេះមួយចំនួន ហើយអាចទៅដល់ច្រើនកន្លែងផ្សេងទៀត ប្រសិនបើម្ចាស់ជំនួយអន្តរជាតិបើកកាបូបប្រាក់របស់ពួកគេខ្លះនោះ។ ឃុំជាច្រើនរហូតមកទល់នឹងពេលនេះ ពុំទាន់មានជំនួយឬក៏ថ្នាំសង្កូវអ្វីទាំងអស់។

កាលពីប៉ុន្មានថ្ងៃមុន យើងបានរកឃើញលំនៅដ្ឋានបណ្តោះអាសន្នមួយដែលមានប្រជាជន២៥៣គ្រួសាររស់នៅយ៉ាងវេទនាខ្វះខាតដោយគ្មាននរណាម្នាក់បានដឹងសោះរហូតមកដល់ពេលនេះ។ ពួកគេទាំងនេះ គឺជាជនជាតិភាគតិចឡាវដែលរស់នៅភូមិប៉យ តាសេក ឃុំបឹងប្រេង ព្រំប្រទល់ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។ ពួកគេបានមកតាំងលំនៅលើវាលភក់យ៉ាងឯកោអស់រយៈពេលជាច្រើនសប្តាហ៍។ កូនៗពួកគេទាំងអស់បានធ្លាក់ខ្លួនឈឺគ្មានសល់ម្នាក់។

ក្តីសង្ឃឹមដ៏តូចមួយបានមកដល់នៅសប្តាហ៍នេះ ជាមួយនឹងចំណងជើង «ស្បៀងអាហារកម្ពុជា» របស់ទីភ្នាក់ងារព័ត៌មាន The Guardian។ ប៉ុន្តែជាទូទៅ កង្វះការផ្សព្វផ្សាយជុំវិញគ្រោះមហន្តរាយដ៏ធំបែបនេះ គឺជារឿងគួរឲ្យភ្ញាក់ផ្អើលបំផុត បើទោះជាវាមានការបកស្រាយយ៉ាងសាមញ្ញថា អ្នកសារព័ត៌មានតំបន់ភាគច្រើនរស់នៅក្នុងក្រុងបាងកក ហើយអ្នកកាសែតកម្ពុជាដ៏តិចតួចស្តួចស្តើងកម្រចេញដំណើរផ្សងព្រេងរុករកព័ត៌មានក្រៅក្រុងណាស់។

លទ្ធផល? បើទោះជាសារព័ត៌មានកម្ពុជាតែងតែចុះអត្ថបទជាច្រើនជុំវិញរឿងទឹកជំនន់ប្រទេសថៃច្រើនជាងអ្វីដែលកំពុងតែប៉ះពាល់ខ្លាំងក្នុងប្រទេសខ្លួន ហើយអ្នកកាសែតក្នុងស្រុកបែរជាភ្ញាក់អារម្មណ៍ចំពោះមហន្តរាយក្នុងប្រទេសរបស់ខ្លួនដោយសារតែអានអត្ថបទកាសែត The Guardian ទៅវិញ។ ប្រហែលជាកម្ពុជាមិនអាចបញ្ជប់គំនិតដែលគិតហួសទៅដល់ពិភពលោកខាងក្រៅបានទេ ដោយត្រូវគិតរំលងអ្នកដែលរស់នៅទីនេះ។

(លោក John Macgregor ជានាយកទំនាក់ទំនងរបស់អង្គការសង្គមស្តារនីតិសម្បទាជនពិការដោយសារសង្គ្រាមនៅកម្ពុជា (CWARS) ដែលសហការជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកចំនួន៤ក្នុងខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ គឺអង្គការ PKO អង្គការ DCO និងអង្គការ Ockenden សម្រាប់កិច្ចប្រឹងប្រែងជួយសង្គ្រោះ។ បច្ចុប្បន្នក្រុមការងារទាំងអស់នេះកំពុងតែរៀបចំគម្រោងស្រោចស្រង់ជីវភាពរស់នៅរបស់ប្រជាជនក្រោយទឹកជំនន់ស្រកសម្រាប់២ខេត្ត)។HR ■

# ធនាគារអភិវឌ្ឍន៍អាស៊ី ផ្ដល់ជំនួយមនុស្សធម៌សង្គ្រោះបន្ទាន់ពាលានដុល្លារដល់ប្រទេសកម្ពុជា



ទឹកជំនន់ឆ្នាំនេះ បានធ្វើឲ្យផ្លូវពីផ្សារក្រោមទៅផ្សារលើទីក្រុងកំពង់ឆ្នាំងត្រូវបានលិចទាំងស្រុងរួមទាំងផ្ទះសម្បែងរបស់ប្រជាពលរដ្ឋជាច្រើនរយខ្នង មន្ទីរពេទ្យ សាលារៀនជាដើម។ រូបថត សំរិទ្ធ

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នឹងផ្ដល់ជំនួយមនុស្សធម៌សង្គ្រោះបន្ទាន់តម្លៃ ៣លានដុល្លារ មកដល់រដ្ឋាភិបាលកម្ពុជា ដើម្បីជួយបំពេញតម្រូវការដ៏ចាំបាច់បំផុតរបស់ប្រទេសនេះ នៅក្រោយទឹកជំនន់ដ៏អាក្រក់បំផុតដែលបានវាយប្រហារប្រទេសមួយនេះនៅក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។

លោក Peter Brimble សេដ្ឋវិទូជាន់ខ្ពស់របស់ ADB ប្រចាំនៅកម្ពុជា បានថ្លែងនៅក្នុងសេចក្ដីប្រកាសព័ត៌មានមួយដែលចេញផ្សាយមកពីទីក្រុងម៉ានីលកាលពីថ្ងៃព្រហស្បតិ៍នេះថា៖ «ទឹកជំនន់ដ៏អាក្រក់នេះ បានជះឥទ្ធិពលយ៉ាងអាក្រក់ទៅលើជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ជាពិសេសប្រជាកសិករក្រីក្រនៅតំបន់ដាច់ស្រយាល។ សហគមន៍ជាច្រើនកំពុងត្រូវការជំនួយបន្ទាន់ ដើម្បីភ្ជាប់ឡើងវិញនូវមជ្ឈមណ្ឌលផ្គត់ផ្គង់ និងដើម្បីកសាងឡើងវិញនូវជីវភាពរស់នៅរបស់ពួកគេ»។

ជំនួយបានមកពីមូលនិធិឆ្លើយតបគ្រោះមហន្តរាយនៅតំបន់អាស៊ីប៉ាស៊ីហ្វិកនេះ នឹងត្រូវបានគេយកទៅប្រើប្រាស់សម្រាប់ផ្គត់ផ្គង់ពូជស្រូវទៅដល់ក្រុមគ្រួសារនៅតាមជនបទ ដែលគ្រាប់ពូជរបស់ប្រជាពលរដ្ឋទាំងនោះ បានខូចបង់អស់ រួមទាំងស្បៀងអាហារ និងផែនការត្រូវការប្រាក់សម្រាប់ធ្វើការងារ ដែលនឹងជួយដល់សហគមន៍រងគ្រោះ អាចជួសជុលផ្លូវថ្នល់ខូចខាតដោយទឹកជំនន់។ ជំនួយក៏នឹងត្រូវបានគេផ្ដល់ផងដែរ សម្រាប់ការជួសជុលបណ្ដោះអាសន្នប្រព័ន្ធធារាសាស្ត្រ។

ប្រជាពលរដ្ឋកម្ពុជាជាង ២៤០នាក់បានស្លាប់ និងជាង ១,៥លាននាក់ បានទទួលរងគ្រោះដោយទឹកជំនន់នៅតាមដងទន្លេមេគង្គ និងទន្លេសំខាន់ៗដទៃទៀត នៅក្នុងរយៈពេល ២ខែកន្លងមកនេះ ដែលបានបំផ្លិចបំផ្លាញ ឬធ្វើឲ្យខូចខាតជាង ១០ភាគរយនៃផលដំណាំស្រូវរបស់កម្ពុជា។

ផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រនៅតាមជនបទ ក៏ទទួលរងគ្រោះយ៉ាងអាក្រក់ផងដែរ ហើយតម្លៃខូចខាតសរុប ត្រូវបានគេវាយតម្លៃថានឹងមានតម្លៃរាប់រយលានដុល្លារ។

ជំនួយសង្គ្រោះបន្ទាន់របស់ ADB នេះ នឹងជួយសហគមន៍ជនបទឲ្យដាំដុះយ៉ាងឆាប់រហ័ស ខណៈកម្មវិធីចំណាយប្រាក់សម្រាប់ការងារជួសជុលនឹងជួយស្ដារឡើងវិញផ្លូវទៅកាន់សេវាសំខាន់ៗ និងផ្ដល់ការងារដែលមានតម្រូវការដ៏អាក្រក់ទាំងនេះ។

ជំនួយនេះ នឹងត្រូវបានគេសហការយ៉ាងជិតស្និទ្ធជាមួយជំនួយដែលផ្ដល់ដោយបណ្ដាដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលដទៃទៀត ក្នុងនោះមានទាំងក្រុមគ្រប់គ្រងគ្រោះមហន្តរាយអង្គការសហប្រជាជាតិផងដែរ។

នៅក្នុងរយៈពេលវែង ប្រទេសកម្ពុជានឹងត្រូវការធនធានដ៏ធំធេងដើម្បីស្ដារខ្លួនចេញពីគ្រោះមហន្តរាយ ហើយ ADB បានផ្ដល់រួចមកហើយនូវការគាំទ្រដល់រដ្ឋាភិបាល ដោយបានដាក់បញ្ចូលគ្នានូវគម្រោងស្ដារឡើងវិញស្បៀងអាហារជាបន្ទាន់ ដែលផ្ដោតលើការជួសជុលផ្លូវថ្នល់និងប្រព័ន្ធធារាសាស្ត្រឡើងវិញ។

ADB ក៏បាននិងកំពុងពិភាក្សាផងដែរនូវសកម្មភាពនានា ដើម្បីអភិវឌ្ឍប្រព័ន្ធទិន្នន័យ និងយន្តការព្រមាន និងឆ្លើយតបទាន់ពេលវេលាដែលនឹងជួយកម្ពុជាឲ្យក្លាយទៅប្រទេសមិនងាយរងគ្រោះដោយទឹកជំនន់ ដែលត្រូវបានគេរំពឹងថានឹងកាន់តែអាក្រក់ថែមទៀតនាពេលអនាគតដោយសារតែលទ្ធផលនៃការប្រែប្រួលអាកាសធាតុ។

មូលនិធិឆ្លើយតបគ្រោះមហន្តរាយតំបន់អាស៊ីប៉ាស៊ីហ្វិករបស់ ADB ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៩នោះ ផ្ដល់នូវជំនួយយ៉ាងលឿនដើម្បីជួយបណ្ដាប្រទេសជាសមាជិកកំពុងអភិវឌ្ឍដែលទទួលរងគ្រោះដោយគ្រោះធម្មជាតិឲ្យសម្រេចបានទៅតាមតម្រូវការភ្លាមៗរបស់ពួកគេ។

មូលនិធិក៏ជួយលុបបំបាត់គម្លាតមុននឹងមានជំនួយកសាងឡើងវិញក្នុងរយៈពេលវែងនៅក្រោយគ្រោះមហន្តរាយ និងការផ្ដួចផ្ដើមការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ៕ DT ■



ផ្ទះមួយនេះកំពុងត្រូវបានសង្គ្រោះបន្ទាប់ពីបាក់ច្រាំងធ្លាក់ចូលទឹកទន្លេនៅអ្នកលឿង។ សូ វិសាល



ប្រជាពលរដ្ឋនៅខណ្ឌឫស្សីកែវបានយកការុងខ្សាច់ដើម្បីទប់ទឹកជំនន់។ រូបថត ស្រេង ម៉េងស្រ៊ុន

# JOB ANNOUNCEMENT

**Account Manager, Accounts Assistant, Budget Analyst, Executive Assistant**
**Grandis Timber limited**
Location: Phnom Penh, Cambodia, Southeast Asia
Contact Phone: 023 882 173
Contact Email: hr@grandist-timber.com
Deadline: **Nove 27, 2011**

**Senior Research Associate**
**Parliamentary Institute of Cambodia**
Address: SENATE, Vimean-rath Chamkar Mon, Preah Norodom Blv., Phnom Penh
Location: Phnom Penh, Cambodia, Southeast Asia
Contact Phone: 012 772 120
Contact Email: pic_jobs@yahoo.com | www.pic.org.kh
Deadline: **Nov 19, 2011**

**Finance Officer**
**SILAKA**
Address: #6S, Street 21,Sangkat Tonle Bassac, Khan Chamkarmon, Phnom Penh, Cambodia
Location: Phnom Penh, Cambodia, Southeast Asia
Contact Phone: (855) 23 217 872 / 210 902
Email: admin@silaka.org
www.silaka.org
Deadline: **Nov 08, 2011**

**National Economic Livelihood Specialist, Monitoring and Evaluation and Communication Officer, Monitoring and Evaluation Officer**
**UNDP**
Address: #53, Pasteur (St. 51), 12302, Phnom Penh
Tel : 023 216 167 Location: Phnom Penh, Cambodia, Southeast Asia
www.un.org.kh/undp/jobs
Deadline: **Nov 21, 2011**

**Monitoring and Evaluation Officer**
**UN Volunteers**
Address: #53, Pasteur (St. 51), 12302, Phnom Penh
Tel: 023 216 167
Location: Phnom Penh, Cambodia, Southeast Asia
Email: unv.kh@undp.org
www.un.org.kh/unv/vacancies
Deadline: **Nov 09, 2011**

**Program Director**
**Cambodian Living Arts (CLA)**
Address: #128G9, Sothearos (St. 3), 12301, Phnom Penh
Location: Phnom Penh, Cambodia, Southeast Asia
Contact Phone: 023 98 60 32
Contact Email: ratanak@cambodianlivingarts.org
Deadline: **Nov 25, 2011**

**Young Professional Officers (Re-Advertise)**
**UNDP Young Professional Officer Program**
Location: Phnom Penh, Cambodia, Southeast Asia
Address: #53, Pasteur (St. 51), 12302, Phnom Penh.
Tel: 023 216 167
www.un.org.kh/undp/work-with-us/jobs#jobs.
Deadline: **Nov 20, 2011**

**Management Specialist**
**UNDP**
Location: Phnom Penh, Cambodia, Southeast Asia
Address: #53, Pasteur (St. 51), 12302, Phnom Penh
Tel: 023 216 167
www.un.org.kh/undp/jobs
Deadline: **Nov 06, 2011**

**International Medical Equipment Specialist**
**Ministry of health**
Address: (Room 207), #151-153, Kampuchea Krom Avenue, Phnom Penh
Location: Phnom Penh, Cambodia, Southeast Asia
Tel: (855-23) 880 262
Contact Email: davy.hssp@online.com.kh
Deadline: **Nov 23, 2011**

**Marketing Manager**
**HGB Trading Co., Ltd**
Address: Building 30, Russian Blvd, Sangkat Phsar Depo 3, khan toul Kork, opposite Neakrovan Pagoda's Gate
Location: Phnom Penh, Cambodia, Southeast Asia
Contact Phone: 012 520 651
Contact Email: chanthan_hgb@yahoo.com
Deadline: **Nov 05, 2011**

**Senior Political Officer**
**The British Embassy**
Location: Phnom Penh, Cambodia, Southeast Asia
Contact Email: vacancy_phnompenh@fco.gov.uk
Website: www.fco.gov.uk
Deadline: **Nov 07, 2011**

**Personal Assistant**
**Sokha Hotels & Resorts**
Address: N°22, Kramoun Sar Street, Phnom Penh, Kingdom of Cambodia
Location: Phnom Penh, Cambodia, Southeast Asia
Phone: + 855 23 998 075
Email: hrmsv@sokhahotels.com
Deadline: **Nov 07, 2011**

**Various Positions**
**Artisans Angkor**
Address: Siem Reap.
Location: Siem Reap., Cambodia, Southeast Asia
Contact Phone: 063 963 330
Contact Email: hr@artisans-dangkor.com
Deadline: **Nov 21, 2011**

**Various Positions**
**EXCHANGE**
Address: The exchange building #47, Street 28 Phnom Penh, Cambodia
Location: Phnom Penh, Cambodia, Southeast Asia
Deadline: **Nov 22, 2011**

**Associate Director, Prevention & Mitigation**
**FHI 360**
Address: #11, St. 302, 12302, Phnom Penh Tel 023 211 914/ 023 212 565
Location: Phnom Penh, Cambodia, Southeast Asia
www.FHI360.org/careercenter
Deadline: **Nov 21, 2011**

**Various Positions**
**The Danish Red Cross (DRC)**
Address: No. 16A, Street 652 corner 271, Sangkat Toeuk Laak III, Phnom Penh
Location: Phnom Penh, Cambodia, Southeast Asia
E: danishrc10@online.com.kh
Deadline: **Nov 07, 2011**

**National Information-Education-Communication Consultant**
UNDP
Location: Phnom Penh, Cambodia, Southeast Asia
Address: #53, Pasteur (St. 51), 12302, Phnom Penh
Tel: 023 216 167
www.un.org.kh/undp/jobs
Deadline: Nov 07, 2011

**English Teacher**
**Phnom Penh International Airport**
Location: Phnom Penh, Cambodia, Southeast Asia
Contact Email: khkpp@gmail.com
Deadline: Nov 25, 2011

**Administration Officer**
**The World Food Program (WFP)**
Address: House 250, Road 63, Phnom Penh
Location: Phnom Penh, Cambodia, Southeast Asia
Contact Phone: 092 945 976
Contact Email: Cambodia.Application@wfp.org
www.174.120.172.7 /~cambodia/
**Deadline: Nov 13, 2011**

**Monitoring Officer**
**COMFREL**
Address: 138, St. 122, 12156, Phnom Penh
Location: Phnom Penh, Cambodia, Southeast Asia
Contact Phone: 012 942 019
Email:comfrel@online.com.kh
www.comfrel.org
**Deadline: Nov 30, 2011**

**Security and Property Administrative Assistant**
Australian Embassy
Address: No. 16B National Assembly Street Sangkat Tonle Bassac, Khan Chamkarmon Phnom Penh
Location: Phnom Penh, Cambodia, Southeast Asia
Contact Phone: 023 213 470
Email: australian.embassy.cambodia@dfat.gov.au
www.cambodia.embassy.gov.au
**Deadline: Nove16, 2011**

**TECHNICAL OFFICER**
**World Health Organization Organisation mondiale de la santé**
Address: Phnom Penh located at 177-179 Pasteur Street
Location: Phnom Penh, Cambodia, Southeast Asia
Contact Phone: (023)216610
Contact Email: whopostmaster@cam.wpro.who.int
**Deadline: Nov 30, 2011**

Export Officer
Golden Rice (Cambodia) Co., Ltd.
Address: #2012 ABC, National Road 5, Sangkat Tuol Sangke, Khan Russey Keo, Phnom Penh, Cambodia,
Location: Phnom Penh, Cambodia, Southeast Asia
Contact Phone: (+855) 23 987 941, 012931957
Contact Email: recruit@goldenricecambodia.com
**Deadline: Nov 14, 2011**

WHO OMS

WORLD HEALTH ORGANIZATION • ORGANISATION MONDIALE DE LA SANTÉ

WHO Cambodia is inviting applications for one position as
**TECHNICAL OFFICER**
**for malaria, vector-borne and parasitic diseases**
**(National Professional Officer NPO NO-C)**

The World Health Organization has been providing technical support to the Government of the Kingdom of Cambodia to support the Ministry of Health (MoH) activities such as elimination of malaria in Cambodia, containing the spread of artemisinin-resistant malaria, control of dengue, control and eventual elimination of Neglected Tropical Diseases (NTDs). This is a full-time position for twelve months beginning as soon as possible with a possibility of extension. The Technical Officer will be based in Phnom Penh, with support costs being met by WHO. Applications from women are encouraged.

**Deadline for applications: 30 November 2011**

**Terms of reference**

To support the National Centre for Parasitology, Entomology and Malaria Control (CNM) of Ministry of Health (MoH) and other national partners including the provincial and operational district level staff in all aspects of malaria, vector-borne and parasitic diseases control. The person selected will:

- Assist in the containment of artemisinin-resistant malaria leading to eventual elimination of all malaria from Cambodia, through WHO collaboration with the National Centre for Parasitology, Entomology and Malaria Control (CNM), including technical assistance to the national program.
- Facilitate training and other capacity-building activities for national and provincial staff on malaria, dengue, neglected tropical diseases (NTDs) and other vector-borne and parasitic diseases.
- Maintain close liaison and facilitate coordination with national counterparts, other implementing partners and stakeholders at all levels, and maintain regular information exchange.

**Qualifications required**
- Medical Doctor with additional training in public health (MPH preferable)

**Experience and skills**
- Minimum 5 years experience in the development and implementation of public health services/interventions, project management
- At least 4 years experience in vector borne disease control.
- Experience in Monitoring and Evaluation of programs
- Data management and analysis skills an advantage.
- Strong interpersonal, organizational and management skills
- Demonstrated self-initiative

**Languages:** Fluent in speaking, reading and writing English and Khmer
**Salary:** Attractive remuneration package.

Interested applicants are required to send a CV to the WHO Representative Office before the deadline. Please indicate the post number in your application. Smoking is not allowed in WHO premises.

**The mission of WHO is the attainment by all peoples of the highest possible level of health.**

*For additional information and full ToR please contact the WHO office in Phnom Penh located at 177-179 Pasteur Street, by email under whopostmaster@cam.wpro.who.int, or by telephone under (023)216610.*

## JOB ANNOUNCEMENT

Golden Rice (Cambodia) Co., Ltd. is an international standard company, equipped with state-of-the-art machinery and technology for drying, milling and packaging rice for export markets. While expanding its activity, the company is looking to recruit dynamic individuals to fill the Export Officer position (02 positions) to be based at Phnom Penh and Kampong Speu:

**ESSENTIAL REQUIREMENTS**
- Biography: Male or Female, minimum 25 years old
- Education: Bachelor of Marketing / Management or equivalent
- Leagues: Chinese and English, fluent in speaking and writing
- Communication and Interpersonal: Good personality, flexible and enthusiastic

**Required knowledge as following:**
- At least 2 years of experience in sales related work
- Experience in export clearance is an advantage
- Good personal relation, self-motivated and clear planning skills
- Good business analysis
- Good computer literacy (Internet & Email, Ms. Office, etc.)
- Good at filing /Keeping document

**Main Duty and Responsibilities:**
- Reply email/ online sales
- Translation (Chinese – English – Khmer )
- Send sample /document
- Researching (Local and Global)
- Meeting with client (Local and oversea)
- Presentation /Guides the client during visiting
- Able to travel to provinces and abroad
- Other task assigned by manager

**APPLICATION INFORMATION**
Interested applicants should submit a cover letter and CV, together with their studying transcript, copy of ID card, copy of their family book, recent photographs (4x6), expected salary and other supporting documents by **November 14, 2011** to the Golden Rice office located at: #2012 ABC, National Road 5, Sangkat Tuol Sangke, Khan Russey Keo, Phnom Penh, **Phone:** (+855) 12 931 957, **Email:** recruit@goldenricecambodia.com and fill the application form at our office. Only short listed applicants will be contacted for an interview. Competitive salary will be offered based on qualifications and experience. Applications will not be returned



ទឹកជំនន់ឆ្នាំនេះ លិចសាលារៀនវត្តអារាម
ផ្ទះ...ជាច្រើននៅកម្ពុជា។ រូបថត ស្រេង ម៉េងស្រ៊ុន